# សហគមន៍ខ្មែរកម្ពុជាក្រោម

**THE KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**


លេខ: ០៧០/១៤ ស.ខ.ក.ក.

# សេចក្តីអំពាវនាវ

ដោយពុំទាន់មានការសុំទោសប្រជានុរាស្ត្រខ្មែរ ឬ ទទួលស្គាល់ការពិតនៃប្រវត្តិសាស្ត្រខ្មែរ ជាលាយលក្ខណ៍អក្សរពីរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ហើយអ្នកនាំពាក្យក្រសួងការបរទេសវៀតណាម នៅតែបន្តបង្គាប់បញ្ជារដ្ឋាភិបាលខ្មែរឲ្យទប់ស្កាត់មិនឲ្យមានការធ្វើបាតុកម្មនៅមុខស្ថានទូតរបស់ខ្លួនដដែលនោះ អង្គការ-សមាគមខ្មែរកម្ពុជាក្រោម និងសម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ នឹងរៀបចំធ្វើមហាបាតុកម្មជាបន្តទៅទៀត នៅថ្ងៃទី០៤, ០៥, ០៦, ០៧, ០៨ ខែតុលា ឆ្នាំ២០១៤។

គោលបំណងនៃបាតុកម្ម:

ទី១- ដង្ហែញត្តិទៅរដ្ឋសភា ដើម្បីស្នើសុំឲ្យរដ្ឋសភាកោះហៅឯកឧត្តមរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មកបំភ្លឺអំពីការបំភ្លៃប្រវត្តិសាស្ត្រខ្មែររបស់រដ្ឋាភិបាលវៀតណាម។

ទី២- ដង្ហែញត្តិទៅជូននាយករដ្ឋមន្ត្រី ស្នើសុំឲ្យផ្តាច់ទំនាក់ទំនងការទូតបណ្តោះអាសន្នជាមួយរដ្ឋាភិបាលវៀតណាម។

ទី៣- ដង្ហែញត្តិទៅស្ថានទូតបារាំង ស្នើសុំឲ្យរដ្ឋាភិបាលបារាំងជួយបញ្ជាក់អំពីកិច្ចព្រមព្រៀងនានារវាងបារាំង-វៀតណាម ដែលឈានដល់ធ្វើច្បាប់លេខ ៤៩/៧៣៣ ក្នុងការកាត់ទឹកដីខ្មែរកម្ពុជាក្រោម ដែលបារាំងហៅថា កូសាំងស៊ីនបារាំង ទៅឲ្យវៀតណាម។

ទី៤- ដង្ហែញត្តិទៅអង្គការសហប្រជាជាតិ ស្នើសុំបញ្ជាក់អំពីការទទួលស្គាល់ទឹកដីខ្មែរកម្ពុជាក្រោមថា ជារបស់វៀតណាមដោយរបៀបណា ព្រោះអ្នកដឹកនាំខ្មែរគ្រប់ជំនាន់មិនដែលបានយល់ព្រមប្រគល់ទឹកដីកម្ពុជាក្រោមឲ្យវៀតណាមម្តងណាឡើយ។

ទី៥- ដង្ហែញត្តិតាមផ្សារនានាក្នុងទីក្រុងភ្នំពេញ សុំឲ្យប្រជារាស្ត្រខ្មែរឈប់ប្រើប្រាស់ទំនិញនិងប្រើប្រាស់សេវាផ្សេងៗរបស់វៀតណាម ដោយមានបិទខិតប័ណ្ណថា ''ខ្មែរឈប់ប្រើប្រាស់ទំនិញវៀតណាម ព្រមទាំងសេវាផ្សេងៗ''។

ដើម្បីឲ្យសកម្មភាពដូចបានទូលប្រគេននិងជម្រាបជូនខាងលើដំណើរការដោយជោគជ័យ ខ្ញុំព្រះករុណា ខ្ញុំសូមលំឱនកាយគោរពអំពាវនាវដល់ព្រះករុណា ព្រះសង្ឃគ្រប់ព្រះអង្គ បងប្អូនជនរួមឈាមខ្មែរទាំងក្នុងនិងក្រៅប្រទេស សូមព្រះមេត្តានិងមេត្តាជួយ បាយ, ទឹក, បដា, ទង់ជាតិ, ទង់ព្រះពុទ្ធសាសនា, អាវយឺត, និងថវិកា តាមលទ្ធភាព ដើម្បីផ្តល់លទ្ធភាពដល់យើងខ្ញុំក្នុងការរៀបចំនិងបង្ហាញពីសាមគ្គីភាពដ៏រឹងមាំនៃប្រជាជាតិខ្មែរ ក្នុងការប្តេជ្ញាការពារកិត្តិយសជាតិ និងប្រវត្តិសាស្ត្រខ្មែរ ហើយក៏ជាសារមួយប្រាប់ទៅរដ្ឋាភិបាលវៀតណាមថា ប្រជារាស្ត្រខ្មែរទាំងអស់មិនអាចទទួលយកនូវការមើលងាយ និងបំភ្លៃប្រវត្តិសាស្ត្រខ្មែរតាមអំពើចិត្តបានឡើយ។

យើងខ្ញុំព្រះករុណា យើងខ្ញុំ សង្ឃឹមយ៉ាងមុតមាំថា ព្រះករុណាគ្រប់ព្រះអង្គ និងបងប្អូនរួមជាតិខ្មែរទាំងអស់ នឹងចូលរួមឧបត្ថម្ភគាំទ្រទាំងស្មារតីទាំងសម្ភារៈ និងថវិកា ដើម្បីជំរុញមហាបាតុកម្មនេះឲ្យបានជោគជ័យជាក់ជាមិនខាន។

*ជយោ! ព្រះរាជាណាចក្រកម្ពុជា*

*កម្ពុជាក្រោមជាទឹកដីខ្មែរ*

*ខ្មែរក្រោម ខ្មែរលើ ខ្មែរកណ្តាលជាខ្មែរតែមួយ*

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែកញ្ញា ព.ស.២៥៥៨ គ.ស.២០១៤

**ថាច់ សេដ្ឋា**

ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម


ទីស្នាក់ការ: ផ្ទះលេខ ៧២ ផ្លូវលេខ ៤២៦A ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី
ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា; ទូរស័ព្ទលេខ: (៨៥៥) ៧៨ ៨៩៨ ៨៨២ / ៩៣ ៤៧ ៤៧ ០៦
អាសយដ្ឋានអ៊ីមែល: thachsetha13@gmail.com, kkcpressoffice@yahoo.com
Website: khmerkromngo.org; Facebook: khmerkkcommunity